ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
CAMBODIAN NATIONAL COUNCIL
FOR CHILDREN

លេខ...១៦៩.......ក.ជ.ក.ក

ភ្នំពេញ ថ្ងៃទី ១៨ ខែ ៧ ឆ្នាំ២០០០

# សេចក្តីសំរេច
# ស្តីពី
# ការបង្កើតអនុគណៈកម្មការ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រិត្យលេខ ៥៦ អនក្របក ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញសេចក្តីប្រកាស លេខ ០១ ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០០ ស្តីពីវិធានការចាត់តាំងអនុវត្ត ផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។

# សំរេច

**ប្រការ ១** : បង្កើតអនុគណៈកម្មការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងគោលបំណង សំរបសំរួល ពិនិត្យតាមដាន ការអនុវត្តន៏ផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង កម្មវិធីផ្សេងៗទៀតដែលពាក់ព័ន្ធ ។ ធ្វើសកម្មភាពជាក់ស្តែងផ្អែកតាមផែនការជាតិ និង ធ្វើការវាយតំលៃលើស្ថានការណ៏ នៃការចាប់ពង្រត់ ការជួញដូរ និង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។